សិលាចារឹកទួលអង្គស្វែង (K.1489)

ទួលអង្គស្វែង មានទីតាំងស្ថិតនៅភូមិដំណាក់អម្ពិល ឃុំស្ដើងជ័យ ស្រុកដើងព្រៃ ខេត្តកំពង់ចាម។ ទីនេះ គឺជាអតីតប្រាសាទបុរាណសម័យមុនអង្គរ (ស.វ.ទី៧-៨) មួយកន្លែង ប៉ុន្តែ បានបាក់បែកស្ទើរទាំងស្រុង និងនៅសល់តែគ្រឿងបង្គំមួយចំនួន និងរចនាសម្ព័ន្ធប្រាសាទ ដូចជា កសិន្ទទឹក និងច្រកចូលខាងកើតជាដើម។ នៅទីតាំងដើមផ្ទាល់ មានបន្សល់ទុកនូវសិលាចារឹកមួយផ្ទាំង ចុះបញ្ជីលេខ K.1489 ដែលសិលាចារឹកនេះអ្នកស្រុកបានយកមកតម្កល់ទុកនៅក្នុងខ្នមអ្នកតា និងបានគោរពបូជាមកទល់បច្ចុប្បន្ន។ តើសិលាចារឹកនេះ មានខ្លឹមសារ និងអត្ថន័យយ៉ាងដូចម្តេចខ្លះ?

អត្ថបទសិលាចារឹកនេះ សរសេរនៅលើបន្ទះថ្មកក់ ដែលមានចារឹកអក្សរលើផ្ទៃទាំងពីរ ដែលមានទម្រង់ជាអក្សរសម័យមុនអង្គរ នាស.វ.ទី៧។ ផ្នែកទី១ មានអក្សរចារឹកចំនួន ៦ បន្ទាត់ ជាភាសាសំស្ក្រឹត បែបគទ្យភាគទ្ធ និងបែបអនុប្តបឆន្ទ សរុបមានចំនួន៧ស្លោក។ រីឯ ផ្នែកទី២ មានអក្សរចារឹកចំនួន ១៣ បន្ទាត់ ជាភាសាខ្មែរ។ ក្នុងនោះ ស្លោកទី១ នៃផ្នែកទី១ (ភាសាសំស្ក្រឹត) ពណ៌នាអំពីការប្រតិស្ឋាន (កសាងព្រះប្រតិមា) ព្រះវិស្ណុ ដោយបានបញ្ជាក់ឆ្នាំកសាងជារបៀបកូតសង្ខ្យាសព្ទថាគរ (ព្រួញសរ)=៥, រស=៦ និងទហន(ភ្លើង) =៣ ពោល គឺស្មើនឹងឆ្នាំ ៥៦៣ នៃមហាសកពជ ដែលត្រូវនឹងគ្រិស្តសកពជ ៦៤១ ពោល គឺត្រូវនឹងរជ្ជកាលព្រះបាទស្រីភវម៌្មទី២ ប៉ុន្តែសិលាចារឹកមិនបានបញ្ជាក់ព្រះនាមព្រះអង្គឡើយ។ ព្រមជាមួយគ្នានេះ សិលាចារឹកបានបញ្ជាក់បន្ថែមថា ប្រតិមាព្រះវិស្ណុបានកសាងឡើងនៅក្នុងខែមាឃ ចំថ្ងៃខ្នើត ថ្ងៃទី២ រោយប់ ក្នុងពេលដែលព្រះចន្ទ្រស្ថិតនៅក្នុងឫក្សបុស្សផ្កាយគ្រោះ ស្ថិតក្នុងមករាសី។

ស្លោកទី២ ពណ៌នាបញ្ជាក់អំពីភាពជាច់ណាត់ថា ពាល់កស្តុការគ្រឿងបូជាទាំងអស់ គឺជាសម្បត្តិរបស់ព្រះជាអម្ចាស់ ពោល គឺគ្មាននរណាមានសិទ្ធិមករឹបអូស ឬល្មើសបំពានបានឡើយ ដោយហោចទៅសូម្បីតែព្រះមហាក្សត្រ។ ស្លោកទី៣ និងទី៣ ជាប្រភេទបទបញ្ញត្តិសីលធម៌អភិសមាចារ ដែលល្មើសក្នុងទេវស្ថាន ពោល គឺជនអ្នកបំផ្លាញសមិទ្ធផល ឬជនជាអ្នកពោលពាក្យកូតកុហក ឬមនុស្សរមិលគុណជាដើម និងត្រូវធ្លាក់ទៅកាន់នរកដរាបណាព្រះចន្ទ្រ និងព្រះអាទិត្យនៅតែមានវត្តមាននៅលើលោក។ ស្លោកទី៥ ពណ៌នាអំពីអ្នកប្រតិស្ឋានព្រះហរិ (ព្រះវិស្ណុ) មានឈ្មោះថា **"អាចារ្យធម៌ទត្ត"** ត្រូវជាកូនប្រុសរបស់ **"អាចារ្យវិស្ណុទត្ត"** និង **"នាងសត្យវតី"**។ ស្លោកទី៦ ពណ៌នាអំពីផលអានិសង្សបុណ្យនៃការបរិត្យាគទាន ដោយការគោរពកក្តី និងទទួលបាន

ផលអានិសង្សរួមគ្នាជាមួយសាច់ញាតិសន្តាន និងទៅកាន់ស្ថានសួគ៌។ ស្ងោកចុងក្រោយ (ទី៧) ពណ៌នាអំពីផលបាបដែលបានកើតចេញពីការបំផ្លាញ ឬការបង្កវិនាសកម្មដល់ព្រះស្រីគោវិន្ទ (ព្រះវិស្ណុ) និងឥទ្ធិពលបានរួមទាំងគ្រួសារសន្តានញាតិ ដែលនឹងត្រូវធ្លាក់ទៅកាន់ពៅវនរក។

ដោយឡែក ចំពោះផ្នែកទី២ ដែលជាអត្ថបទភាសាខ្មែរវិញ គឺពណ៌នាអំពីតង្វាយជាមូលនិធិរបស់លោកអាចារ្យធម្មទត្ត និងម្តាយឪពុករបស់លោក គឺ អាចារ្យវិស្ណុទត្ត និងព្រះហញសត្យវតី។ មូលនិធិទាំងនេះ មានដូចជា អ្នកបម្រើប្រុសស្រី គោ ដីស្រែ ចម្ការ អំបិល ស្ងោ ស្រូវ លូ ប្រេង កន្ទេល ខ្នើយ សម្លៀកបំពាក់ ជាដើម។

អត្ថបទចារឹក និងសេចក្តីប្រែ

ផ្នែកទី១

១. ភជ្ជាកោកេន បិណ្ឌេនហានវសេកវៃរង្គិតំវត្សរាណាំ
មាឃស្សាខ្យេចបក្បេចបទ្ធិនិវសេវរិតេយាមិនីសាយនាស្សាតិ
សេន្ទម្បម្បស្មនាយំត្រិភុវនវតស្ស្ថាបិតស្តត្រសក្រិះ
វិម្ភុយ្យោតៃកុកស្មេច្ចិះចិតមកវេណោនិតេនត្រហាណាំ។

ប្រែថា៖ ក្នុងមហាសករាជឆ្នាំ ៥៦៣ (ទហនវសគរ គឺទហន=៣, វស=៦, គរ=៥) ក្នុងខែមាឃ ខ្នើត ថ្ងៃទី២ (ទ្វិទិវស) វេលាយប់ ក្នុងខណៈដែលព្រះចន្ទ្រស្ថិតក្នុងឫក្សបុស្យ (បុឫ) (ព្រះប្រតិមា) ព្រះវិស្ណុដ៏មានសិរីសួស្តី ដែលជាម្ចាស់នៃត្រៃភព ត្រូវបានប្រតិស្ឋានឡើងយ៉ាងល្អត្រឹមត្រូវក្នុងខណៈដែលគ្រហៈទាំងឡាយស្ថិតក្នុងមករាសី។

២. យទ្ធត្តំក្រមជាធិក្បោ តឧតោបេនតទ្ធនំ
តឧហាយ៌ន្ធបេជាបិ កឹបុនស្សុតវាន្ធវៃះ។

ប្រែថា៖ ទ្រព្យសម្បត្តិទាំងឡាយណាដែលបានថ្វាយចំពោះព្រះអង្គហើយនោះ ទ្រព្យនោះសូម្បីតែព្រះនរបតី (ព្រះមហាក្សត្រ) ក៏មិនអាចរឹបអូសយកទៅវិញបានដែរ ចុះទម្រាំតែពួកកូនចៅឬញាតិសន្តានដទៃទៀត តើអាចយកទៅបានម្តេចនឹងកើត?

៣. វាក.....ក្ខតឃ្នក្ខ កុ.....តេត្រៃយៈ
ជរកាត្មនិវត្តិតេ យាវត្បោមនិវាករៈ។

ប្រែថា៖ *បុគ្គលណាដែលពោលពាក្យកូតកុហក..... និងជាមនុស្សរមិលគុណ ..... បុគ្គលទាំងនោះនឹងមិនអាចងើបចេញពីនរកបានឡើយ ដរាបណាព្រះចន្ទ្រ និងព្រះអាទិត្យនៅតែមានវត្តមាននៅលើលោក។*

៤. សត្រានៃច្រាក្យវ្រត្តាតាំ កេនដំយៈកកេតិច
សចាបក្ខត្បាបតរៈ ចាកកេនឥវស្ងួតមិ។

ប្រែថា៖ *បុគ្គលណាដែលមកបំផ្លាញ ឬធ្វើឱ្យបែកបាក់នូវសទ្ធាទានដែលគេបានធ្វើហើយពីមុនមក បុគ្គលនោះចាត់ទុកថាជាអ្នកធ្វើបាបដ៏អាក្រក់បំផុត (ហើយនឹងទទួលផលបាបនោះគ្រប់ទម្រង់រសជាតិ) ប្រៀបដូចជាការចម្អិនអាហារប្រភេទផ្សេងៗគ្នា (អាហារដែលដាក់ក្នុងឆ្នាំងតែមួយតែបើប្រើភ្លើងខុសគ្នា ឬគ្រឿងផ្សំខុសគ្នា លទ្ធផល (រសជាតិ) ក៏ចេញមកខុសគ្នា យ៉ាងណាមិញនឹងទទួលរងទុក្ខវេទនាគ្រប់ទម្រង់។*

៥. អាចាយ៌្យវិម្ភុឧត្តស្យ សត្យវត្ត្យាក្ខយស្សុតៈ
ឩម្ម៉ឧត្តាហ្វយោទ្ធាក្យ ឆ្ពេជាយំស្តាប្យតេហរិៈ។

ប្រែថា៖ *លោកដែលមានឈ្មោះថា **ធម៌ទត្ត** ដែលជាកូនប្រុសរបស់លោកអាចារ្យ **វិស្ណុទត្ត** និងនាង **សត្យវតី** គឺជាអ្នកបានប្រតិស្ឋានទូវព្រះហរិ (ព្រះវិស្ណុ) អង្គនេះឡើង។*

៦. យោឧត្តាវ្ហេវេសម្យ ក្ខាសាជាសិឩជានំ ច
កេ្សត្រាភមបកុន្ធក្តា ស្វក្តិម្យាតិសវាន្ធវៃ។

ប្រែថា៖ *បុគ្គលណាដែលបានថ្វាយចំពោះព្រះវិស្ណុ នូវខ្ញុំបម្រើប្រុស ខ្ញុំបម្រើស្រី ទ្រព្យធនស្រែចម្ការ ច្បារដំណាំ និងសត្វពាហនៈទាំងឡាយ ដោយកក្តីភាពបុគ្គលនោះព្រមទាំងញាតិសន្តានទាំងអស់ នឹងបានទៅកាន់ស្ថានសួគ៌។*

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

៧.	ក្រីគោវិន្ទស្សយទ្រវ្យ	ឝ្ឝ្កិត្សម្បាឝិយេមាវេ
	ត្សវ្ថៃប្រែកុលសន្តានៃះ	តីវ្រយោតុ សវៅវវម។ ๐๛

ប្រែថា៖ *ប៉ុន្តែ ប្រសិនបើជនណាម្នាក់ ហ៊ានលួចបន្លំយកនូវទ្រព្យសម្បត្តិ ឬសូម្បីតែផ្កាបូជា ដែលជាតង្វាយថ្វាយចំពោះព្រះស្រីគោវិន្ទ (ព្រះវិស្ណុ) នេះ សូមឱ្យបុគ្គលនោះ ព្រមទាំងក្រុមគ្រួសារ និងញាតិសន្តានទាំងអស់ ធ្លាក់ទៅរងទុក្ខវេទនាដ៏ខ្លាំងក្លា (តីវ្រ) ក្នុងវៅវុ:នរកកុំខានឡើយ!*

អត្ថបទចារឹក និងសេចក្តីប្រែ

ផ្នែកទី២

១. នីប្រែកម្រែតាឝីអញក្រីគោវិន្ទស្វាមិមឝិអាចាយ្យឝម្ម៉ឝត្តឝុកឝុទ្រវ្យអាចាយ្យនៃយ ឱយិបុណ្យ

២. អាចាយ្យវ្ឈ្ម៉ុឝត្ត ឱយិបុណ្យប្រែហញ្ញសត្យវតិកេយឝមានអាចាយ្យឝម្ម៉ឝត្តអំនោ

៣. យិតប្រែកុំយោឝវាក្ខបិត៑កុំតកន្តែកុឝឝ្ឋ៑កុកន្តេឝី៑កុស្មោហ្ល្វ៑កុអន្ទ្រោកិ៑

៤. កោនិផោឝីចំឝក្តិសិវាកំវញ្ជិម្ខនិវាវក្កាវតីកាក្យត្ថុរ៑០ស្រែសន្ទែ៤ជំរិឝីអន្តកំលុឝី កុ

៥. ផោឝីកនិអំនោយិតប្រែផោឝីកិុជាកិុតេលប្រែតិវន្ធសំអាយិតប្រែកម្រែតាឝីអញ្ជិក្រីឝក្រែតីថ៌ស្វាមិប្រែអា
ចា

៦. យ្យឝម្ម៉ឝត្តស្រ្ញសត្រែកេប្រែតកិុសំវត្សរតមោយ្យទ្រោឝីចំវេន្តកិុទ្ធាឝតីរិមុក្រែហកៃ៦ឆ្នោឝី៤សឆ្ន..ត្នោឝី

៧. អំបេលិហ្វាឝី១៤ស្វាស្ថិកិ៤ឆ្ងោឝិ១បវេឝីបញ្ចតិអន្តោឝីមាសិ៤បវេឝីមឝុបក្ខមាសិ៨ថ្ងៃដោរអន្តោឝី

៨. ៥ក្រែយាឝុឧត្សវវេប្រែតកិុខេតចោន្ធស្រ្ញសោត្នោឝី១០ឦ្ឋចិ១៤ស្វាប្រែឆ្ងោឝិ៤ត្នះ៤ភវតចោសិឆ្ងោឝិ៤

៩. ..ការិឆ្នោឝិ៤បវេឝីមាសិ៥ថ្ងៃដោរអន្ធឝី១០បវេឝីបញ្ចតិមាសិ២សន្តេកិ៨៦អំបេលិហ្វាឝី៤ច

១០. ..ស្រែសន្ទែ១ល្ងោត្នោឝ៦វម៉ាំបំឆោសិបំជុះចន្ទេកិយៅ៤ក្នេយិ២កន្ទេល៦បវេឝីមាសិ២ស្រែ

១១. សន្ទែ១០.....តល្ងោត្នោឝី១វម៉ាំកេប្រែនៃចន្ទេកិយៅ២ស្ពំត្បោឝីយៅ១កឈ្ឈាយថ្ងយៅ១

១២. ឋ្នឝីសំរុកិ៦ឧថ្ងាយ៤ឆោឝី៤ច្រាសិ២អ្វាកិ២តយោឝី៦លញ្ចោឝី៦ឆ្ងោយិចាយិ២ចរ៦ឝកីត្តិ:

១៣. កៃ៥ក្រែចាសិកន្ធិ២ចឆ្ពសិបុរិក្ខិតិកំឆោតិអ្នបិបញ្ចត្តឆ្ងលិកោក..តិស្តិតិតកិឧត្សវ។

សេចក្តីប្រែ

(១-៣) ព្រះកម្រតាឝីអញ្ជ្រីគោវិន្ទស្វាមិ ដែលលោកអាចារ្យឝម្ម៉ទត្តបានរៀបចំចាត់ចែងទុកជាក់ និងទ្រព្យរបស់លោកអាចារ្យផ្សេងទៀតបានផ្តល់ឱ្យបុណ្យអាចារ្យវ្ឈ្ម៉ុទត្ត (ជាឪពុកអាចារ្យឝម៌ទត្ត) ឱ្យបុណ្យ ព្រះហញ្ញសត្យវតី (នាងសត្យវតីជាម្តាយរបស់អាចារ្យឝម៌ទត្ត) អ្នកដែលជា

យជមាណ (ម្ចាស់មូលនិធិ) អាចារ្យធម្មទត្ត អំណោយថ្វាយអ្នកបម្រើដល់ព្រះ (ព្រះកម្រតាង៑អញ្ជ្រៃគោរិន្ទស្វាមិ=ព្រះកុណ្ឌា ជាអវតាររបស់ព្រះនរាយណ៍) មានដូចខាងក្រោមនេះ៖

(៣-១០) អ្នកបម្រើបុរស មាន វាក្ងបិតម្នាក់។ អ្នកបម្រើនារី មាន កុជទ្ធ១ កុកន្តេង១ កុស្មោរៀ១ កុអង្រោក១ និងកូនគាត់នោះផង។ អ្នកចំទកបុរស មាន វាកំវញ ជាប្អូនរបស់វាវក្ក វាតីភាគ្យ។ (តង្វាយផ្សេងទៀត) មាន គោ១០ក្បាល ដីស្រែ៤សន្រែ ទំរឹង(ចម្ការទ្រើង)អន្ត នៅខាងក្នុងផង។ គន (គណ)អ្ន កបម្រើជាអំណោយថ្វាយដល់ព្រះផង ហើយដែលបានប្រតិពន្ធរួមគ្នាជាមួយនិងព្រះកម្រតាង៑អញ្ជ្រៃចក្រតីចំស្វាមិ (ព្រះនារាយណ៍) ដែលព្រះអាចារ្យធម្មទត្ត បានថ្វាយបូជាមានស្រូវសម្រាប់ពិធីបុណ្យបូជាដល់ព្រះក្នុង១ឆ្នាំ (សំវត្សរត មោយ្យ) និងសម្រាប់បុណ្យចម្រើននៅក្នុងថ្ងៃទី១២ នៃថ្ងៃថ្លៃវិមុវគ្រហ ចំនួន២៦ និង៥ថ្នោង..ត្នោង អំបិលចំនួន១៤ ហ្វាង (វាង+ហ+វាង>ពាង=ក្រឡ?) ស្វាចំនួន៩ស្លឹក ១ផ្ទួន ប្រេងបញ្ចុតអន្តោងចំនួន៤មាស ប្រេងមធុបក្ក ចំនួន៨មាស ស្ករឆ្ងូចំនួន៦អន្តោង ក្រយា និងឧត្សរវេរ (ប្រគេនថ្វាយ) ដល់ព្រះគឺ សម្រាប់៤ខែ ស្រូវសោចំនួន១០ត្នោង ភ្នួចចំនួន១៥ ស្វាព្រះចំនួន៤ផ្ទួន៤ត្នះ។ សម្រាប់ព្រះកគវត ដែលបួស (បព្វជិត) ចំនួន៤ផ្ទួន ការិ ថ្នោនចំនួន៤ ប្រេងចំនួន៥មាស ស្ករឆ្ងូចំនួន១០អង្គង ប្រេងបញ្ចុតចំនួន ២មាស សណ្តែកចំនួន២ដេ (កញ្ជើ) អំបិលចំនួន៤ហ្វាង ច..ស្រែ១សន្រែ ល្អ២ត្នោង។

(១០-១៣) វជ្ជំបំនោស បំជោះ (បព្វជិតអ្នកធ្វើពិធីបំជុះ (ពិធីលាងជម្រះបាប) សម្រាប់រដូវក្ងៀងឬវស្សា) មាន សម្លៀកបំពាក់៤យៅ ខ្នើយ២ កន្ទេល២ ប្រេង២មាស ស្រែ១០ សន្រែ .. ល្អ១ ត្នោង។ ក្នុងវជ្ជំ (សម្រាប់រដូវក្ងៀងឬវស្សា) ថ្វាយដល់ព្រះផ្សេងៗបន្ថែមទៀតមាន សម្លៀកបំពាក់ ២យៅ ស្នំត្បោង១យៅ កន្ទាយជ្រ១យៅ ផ្នេងសំរុង៦ ទង្គាយ៤ នោង៤ច្រាស៊ិ២ អ្ងាក២ តយោង២ លញ្ជោង៦ ច្តោយបាយ២ ចរា២ ជកីត្តិះ កែ៥ ក្របាស កន្ទិ ២ ចន្លុស បុរ ក្ងិត កំទោត អ្នកបញ្ជុត្ត ង្គ្រល គោគ..ជាបញ្ជីស្តិតិសម្រាប់ឧត្សវ (បុណ្យ)។

សរុបជារួមមក សិលាចារឹកទួលអង្គស្វែង (K.1489) បានបង្ហាញឱ្យឃើញយ៉ាងច្បាស់អំពីជីវភាព និងជំនឿរបស់សង្គមខ្មែរនាស.វ.ទី៧។ តាមរយៈខ្លឹមសារទាំងពីរផ្នែក គឺផ្នែកភាសាសំស្ក្រឹត និងភាសាខ្មែរ បានបង្ហាញអំពីការកសាង និងការតម្កល់ព្រះវិស្ណុ ឬព្រះស្រីគោរិន្ទស្វាមិ ព្រមទាំងការបង្កើតមូលនិធិទ្រព្យសម្បត្តិ ដូចជា អ្នកបម្រើ គោ ដីស្រែចម្ការ និងគ្រឿងបូជាផ្សេងៗ ដើម្បី

អត្ថបទដោយ៖ កំ វណ្ណាវ៉ា និងព្រះតេជគុណ អេង សុគង់

ជានាដល់កិច្ចប្រតិបត្តិ និងកិច្ចពិធីបូជាប្រចាំឆ្នាំ។ ក្រៅអំពីនេះ សិលាចារឹកបានបង្ហាញពីទិដ្ឋភាពផ្លូវច្បាប់ និងសីលធម៌បុរាណ តាមរយៈការដាក់បទបញ្ញត្តិហាមឃាត់យ៉ាងដាច់ណាត់មិនឱ្យមានការរឹបអូស ឬបំផ្ទិចបំផ្លាញទ្រព្យសម្បត្តិរបស់ទេវស្ថាន សូម្បីតែព្រះមហាក្សត្រក៏គ្មានសិទ្ធិដែរ។ បន្ថែមពីនេះ សិលាចារឹកបានបង្ហាញអំពីការដាក់បណ្តាសាចំពោះជនណាដែលប្រព្រឹត្តិអំពើទុច្ចរឹតប្រឆាំងនឹងសមិទ្ធផលទាំងនោះផងដែរ។

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ កំ វណ្ណាវ៉ា និងព្រះតេជគុណ អេង សុគង់



រូបលេខ១៖ ទួលអង្គស្វែង (ខេត្តកំពង់ចាម)




រូបលេខ២៖ ខ្ទមអ្នកតានៅលើទួលអង្គស្វែង ទីតាំងតម្កល់សិលាចារឹក K.1489 នាបច្ចុប្បន្ន

អត្ថបទដោយ៖ កំ វណ្ណាវ៉ា និងព្រះតេជគុណ អេង សុគង់




រូបលេខ៣៖ សិលាចារឹកទួលអង្គស្វែង K.1489 (តម្កល់នៅក្នុងខ្នមអ្នកតាលើទួលប្រាសាទ)



រូបលេខ៤៖ សំណៅផ្តិតសិលាចារឹកទួលអង្គស្វែង K.1489 ផ្នែកទី១ និងទី២រួមបញ្ចូលគ្នា
(ផ្តិតដោយ៖ កំ វណ្ណារ៉ា)

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់



រូបលេខ៥៖ លម្អិតសំណៅផ្តិតសិលាចារឹកទួលអង្គស្វែង K.1489 ផ្នែកទី២ ឬផ្នែកភាសាខ្មែរ (ផ្តិតដោយ៖ កំ វណ្ណាវ៉ា)

អរិយធម៌ខ្មែរ
KHMER CIVILIZATION